អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-Dec-2012, 16:11
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៨)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (18)

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Judge Florence Ndepele Mwachande MUMBA
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១២
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបើកសវនាការលើ បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការសំណុំរឿង០០២/០១ ឬស្នើសុំឲ្យដាក់ចម្លើយតបរួម

---

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ជនជាប់ចោទ**

អៀង សារី

ខៀវ សំផន

នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**សហមេធាវីជនជាប់ចោទ អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ

Michiel PESTMAN

Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Arthur VERCKEN

Jacques VERGÈS

Anta GUISS

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល") និង ("អ.វ.ត.ក") បានទទួលសំណើមួយដែលដាក់ដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្នើសុំឲ្យបើកសវនាការជាសាធារណៈលើបណ្តឹងសាទុក្ខភ្លាមៗ ដែលសហព្រះរាជអាជ្ញាបានដាក់កាលពីថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង០០២/០១[1]។ ជាម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញាស្នើសុំដាក់ការឆ្លើយតបរួមទៅនឹងសារណាតបរបស់ជនជាប់ចោទទាំងបីរូប ដែលឆ្លើយតបនឹងបណ្តឹងសាទុក្ខភ្លាមៗ[2]។ កាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ជនជាប់ចោទ អៀង សារី បានដាក់សារណាតបទៅនឹងសំណើសុំ[3] ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានដាក់ការឆ្លើយតបទៅវិញនោះទេ។ ជនជាប់ចោទ នួន ជា និងជនជាប់ចោទ ខៀវ សំផន មិនបានធ្វើការឆ្លើយតបទៅនឹងសំណើសុំនោះទេ។

2. សហព្រះរាជអាជ្ញាលើកឡើងថា សំណើរបស់ខ្លួនសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈលើបណ្តឹងសាទុក្ខភ្លាមៗនេះ គឺ"ដោយសារតែមានសារៈសំខាន់លើបញ្ហាទាំងនេះចំពោះ

[1] សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យធ្វើសវនាការជាសាធារណៈ លើបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង ០០២/០១ ឬសំណើម្យ៉ាងទៀតសុំដាក់ចម្លើយតបរួម ទៅនឹងចម្លើយតបទាំង៣របស់មេធាវីការពារក្តី ឯកសារ E163/5/1/6 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សំណើសុំ") កថាខណ្ឌ ៣។ បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះ ក្តី នៅក្នុងសំណុំរឿងលេខ ០០២/០១ មានឧបសម្ពន្ធ (I) និងឧបសម្ពន្ធសម្ងាត់ (II) ឯកសារ E163/5/1/1 ចុះថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("បណ្តឹងសាទុក្ខភ្លាមៗ")។

[2] សំណើសុំ កថាខណ្ឌ ៤។

[3] ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យធ្វើសវនាការជាសាធារណៈលើបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង ០០២/០១ ឬសំណើម្យ៉ាងទៀតសុំដាក់ចម្លើយតបរួមទៅនឹងចម្លើយតបទាំងបីរបស់មេធាវីការពារក្តី ឯកសារ E163/5/1/7 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("ចម្លើយតប")។

គ្រប់ភាគី និងប្រជាជនកម្ពុជា"[4]។ ជនជាប់ចោទ អៀង សារី បានឆ្លើយតបថា អង្គជំនុំជម្រះតុលាការកំពូលមិនមានយុត្តិកម្មដើម្បីសម្រេចឱ្យបើកសវនាការនៅក្នុងករណីនេះទេ[5]។

3. ចាប់តាំងពីពេលដាក់សំណើសុំ សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបដាច់ដោយឡែកពីគ្នាទៅនឹងសារណាតបរបស់ជនជាប់ចោទទាំងបី ដែលឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ[6]។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល បណ្តឹងសាទុក្ខភ្លាមៗត្រូវបានសង្ខេបយ៉ាងពេញលេញ និងមានការដាក់សារណាជាសាធារណៈច្រើន ដែលបង្ហាញយ៉ាងគ្រប់គ្រាន់អំពីមូលហេតុច្បាស់លាស់តែមួយគត់របស់សហព្រះរាជអាជ្ញាសម្រាប់ស្នើសុំឱ្យបើកសវនាការ ពោលគឺសារៈសំខាន់នៃបញ្ហាដែលបានលើកឡើង។ ដោយរំឭកថា បណ្តឹងសាទុក្ខភ្លាមៗអាចត្រូវបានសម្រេចផ្អែកតាមមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[7] និងដោយបានពិនិត្យមើលការដាក់ឯកសារពាក់ព័ន្ធទាំងអស់ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នៅដំណាក់

---

[4] សំណើ កថាខណ្ឌ ៣។ សហព្រះរាជអាជ្ញាក៏បានយោងផងដែរលើមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក វិសោធនកម្មលើកទី ៧ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ដែលបានចែងថា "ការឆ្លើយតបទៅនឹងចម្លើយតបត្រូវបានអនុញ្ញាតតែក្នុងករណីដែលមិនមានការស្នើសុំឱ្យមានការដេញដោលផ្ទាល់មាត់ ប៉ុណ្ណោះ ហើយការឆ្លើយតបនោះត្រូវដាក់ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងនៃចម្លើយតបនោះ ដែលត្រូវឆ្លើយតប"។ *សូមមើល* សំណើ កថាខណ្ឌ ៣ និង ជើងទំព័រលេខ ៥។

[5] ចម្លើយតប កថាខណ្ឌ ៤ ដល់ ៧។ អៀង សារី បានលើកឡើងថែមទៀតថា "អង្គជំនុំជម្រះតុលាការកំពូល ពុំមានយុត្តាធិការក្នុងការស្តាប់សក្ខីកម្មលើសំណើផ្សេងដាច់ដោយឡែក[...] នៅក្នុងដំណាក់កាល នៃកិច្ចដំណើរការនីតិវិធី នាពេលនេះទេ" (សូមមើល ចម្លើយតប កថាខណ្ឌ ១ ជើងទំព័រលេខ ២) និងថា សហព្រះរាជអាជ្ញាគួរដាក់បញ្ចូលសំណើ នេះជាផ្នែកមួយនៃបណ្តឹងសាទុក្ខរបស់ខ្លួន។ *សូមមើល* ចម្លើយតប កថាខណ្ឌ ២ ដល់ ៣។ អង្គជំនុំជម្រះតុលាការកំពូល ពុំឯកភាពទេ។ សំណើសុំបើកសវនាការជាសាធារណៈនៅក្នុងករណីនេះ គឺកើតចេញមកពីបណ្តឹងសាទុក្ខភ្លាមៗខ្លួនឯង តែម្តង ហេតុដូច្នេះហើយ ត្រូវតែជាផ្នែកមួយនៃបណ្តឹងសាទុក្ខនោះជាចាំបាច់។

[6] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ អៀង សារី អំពីបណ្តឹងសាទុក្ខពាក់ព័ន្ធ នឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿង លេខ ០០២/០១ ឯកសារ E163/5/1/8 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា ចំពោះបណ្តឹងសាទុក្ខ ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿង លេខ ០០២/០១ ឯកសារ E163/5/1/10 ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ ខៀវ សំផន ចំពោះបណ្តឹង សាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង លេខ ០០២/០១ ឯកសារ E163/5/1/11 ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២។

[7] វិធាន១០៩(១)នៃវិធានផ្ទៃក្នុង អ.វ.ត.ក វិសោធនកម្មលើកទី៨ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១។

កាលនេះ មិនមានតម្រូវការណាមួយដើម្បីសួរដេញដោលបន្ថែមទៀតលើបណ្ដឹងសាទុក្ខភ្លាមៗនោះទេ។ ហេតុនេះ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលតម្រូវឲ្យដាក់សារណាបន្ថែមនៅដំណាក់កាលក្រោយទៀត ភាគីនឹងទទួលបាននូវការជូនដំណឹងនេះ។

4. យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូល **បដិសេធ** សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបើកសវនាការលើបណ្ដឹងសាទុក្ខភ្លាមៗ និង**បដិសេធចោល**សំណើម្យ៉ាងទៀតសុំដាក់ការឆ្លើយតបរួមមួយចោល ជាអាសាបង់។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**KONG Srim**